**២- កាតព្វកិច្ចម្ចាស់មធ្យោបាយធ្វើដំណើរ**

- ម្ចាស់មធ្យោបាយធ្វើដំណើរត្រូវបំពេញប្រតិវេទន៍គយសង្ខេប(ចេញ) ដូចមានភ្ជាប់ជាមួយសារាចរណែនាំនេះ រួចចុះហត្ថលេខា និងប្រគល់ជូនមន្ត្រីគយមានសមត្ថកិច្ចច្រកចេញ ដោយភ្ជាប់ជាមួយនូវច្បាប់ចម្លងនៃ÷
  - លិខិតឆ្លងដែន លិខិតបើកផ្លូវឬលិខិតប្រហាក់ប្រហែលនិងអត្តសញ្ញាណប័ណ្ណ
  - ប័ណ្ណសម្គាល់មធ្យោបាយធ្វើដំណើរ ឬប័ណ្ណសម្គាល់ប្រហាក់ប្រហែល (លើកលែងទោចក្រយាន)
  - ប័ណ្ណបើកបរយានយន្ត។
- ក្នុងរយៈពេលស្នាក់នៅបណ្តោះអាសន្ននៅបរទេស ម្ចាស់មធ្យោបាយធ្វើដំណើរឬតំណាងត្រូវរក្សាប្រតិវេទន៍គយសង្ខេប និងត្រូវប្រគល់ជូនមន្ត្រីគយច្រកចូលមកវិញ សម្រាប់ជម្រះបែបបទគយចេញបណ្តោះអាសន្ន។ ប្រសិនបើម្ចាស់មធ្យោបាយធ្វើដំណើរមិនគោរពតាមការណែនាំនេះទេ នឹងត្រូវទទួលរងនូវការពិន័យតាមច្បាប់ជាធរមាន។
- ក្នុងករណីមានតម្រូវការប្តូរច្រកចូល ឬពន្យារពេលនៃការចូលមកវិញ ម្ចាស់មធ្យោបាយធ្វើដំណើរ ឬតំណាងត្រូវសុំការអនុញ្ញាតជាមុនពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

- ការហួសសុពលភាពនៃការចូលមកវិញ នឹងត្រូវរងការពិន័យក្នុងមួយថ្ងៃចំនួន ១០ ០០០រៀល សម្រាប់ទោចក្រយាន ចំនួន ២០ ០០០រៀល សម្រាប់ទោចក្រយានយន្ត និងចំនួន ៥០ ០០០រៀល សម្រាប់មធ្យោបាយធ្វើដំណើរផ្សេងទៀត ដោយមន្ត្រីគយមានសមត្ថកិច្ចនៅច្រកចូល។

**៣- ការិយាល័យគយនិងរដ្ឋាករច្រកចេញ**

- ប្រធានការិយាល័យគយនិងរដ្ឋាករច្រកចេញ មានសិទ្ធិពិនិត្យនិងសម្រេចនៅនឹងកន្លែងលើការអនុញ្ញាតឱ្យចេញ បណ្តោះអាសន្ននៃមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនរបស់ភ្ញៀវទេសចរ។
- ក្នុងករណីយល់ថាចាំបាច់ ការិយាល័យគយនិងរដ្ឋាករច្រកចេញត្រូវសុំការសម្រេចជាមុនពីប្រធានសាខាគយនិងរដ្ឋាករពាក់ព័ន្ធ។ ក្នុងករណីជួបការលំបាក សាខាគយនិងរដ្ឋាករពាក់ព័ន្ធត្រូវរាយការណ៍ជូនអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីសុំការណែនាំ។
- មន្ត្រីគយត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ឯកសារជាមួយមធ្យោបាយធ្វើដំណើរជាក់ស្តែង។ ក្នុងករណីរកពុំឃើញ មានភាពមិនប្រក្រតី មន្ត្រីគយត្រូវធ្វើទម្រង់ការចេញតាមបទប្បញ្ញត្តិជាធរមាន។
- ជូនដំណឹងដល់មន្ត្រីគយច្រកចូលមកវិញពីការអនុញ្ញាតឱ្យចេញបណ្តោះអាសន្ន និងកាលបរិច្ឆេទនៃការចូលមកវិញនៃមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួនរបស់ភ្ញៀវទេសចរ។

**៤- ការិយាល័យគយនិងរដ្ឋាករច្រកចូល**

- ទទួលប្រតិវេទន៍គយសង្ខេប(ចេញ) ពីម្ចាស់មធ្យោបាយធ្វើដំណើរ ឬតំណាងរួចធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ឯកសារជាមួយមធ្យោបាយធ្វើដំណើរជាក់ស្តែង។ ក្នុងករណីរកពុំឃើញមានភាពមិនប្រក្រតី មន្ត្រីគយត្រូវធ្វើទម្រង់ការចូលតាមបទប្បញ្ញត្តិជាធរមាន។
- មន្ត្រីគយត្រូវដករក្សាទុកនូវប្រតិវេទន៍គយសង្ខេប រួមទាំងច្បាប់ចម្លងនៃឯកសារភ្ជាប់។

ក្នុងអន្តរកាលដែលការផ្តល់ប័ណ្ណធានារ៉ាប់រងសម្រាប់មធ្យោបាយធ្វើដំណើររបស់ភ្ញៀវទេសចរ ចូលមកព្រះរាជាណាចក្រកម្ពុជានៅពុំទាន់អាចអនុវត្តបាន អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាត្រូវបន្តអនុវត្តនីតិវិធីគយជាធរមាន ចំពោះមធ្យោបាយធ្វើដំណើរទាំងនោះ។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវគ្រប់គ្រងនិងចាត់ចែងផ្សព្វផ្សាយដល់គ្រប់អង្គភាពគយនិងរដ្ឋាករ ព្រមទាំងបុគ្គលពាក់ព័ន្ធ ឱ្យទទួលអនុវត្តតាមខ្លឹមសារនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ តទៅ។

ថ្ងៃ [illegible] ១ [illegible] ១ ០ ១ ០ ១ ០

# ឧបសម្ព័ន្ធ

(អមសារាចរណែនាំលេខ ០១២ សមាវ ចុះថ្ងៃទី ៣១ ខែ ១២ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)

## ប្រតិវេទន៍គយសង្ខេប

### សម្រាប់មធ្យោបាយធ្វើដំណើរចូល-ចេញបណ្តោះអាសន្នរបស់ភ្ញៀវទេសចរ

### SUMMARY CUSTOMS DECLARATION FORM
For Temporary Entry-Exit of Conveyance of Tourist

ការិយាល័យគយនិងរដ្ឋាករ.....
Customs and Excise Office

លេខចុះបញ្ជី Registration No:.....

☐ ចូល ENTRY ☐ ចេញ EXIT

ច្រកចូល Entry Border Gate..... ថ្ងៃខែឆ្នាំចូល Date of Entry.....
ច្រកចេញ Exit Border Gate..... ថ្ងៃខែឆ្នាំចេញ Date of Exit.....

**1- ព័ត៌មានមធ្យោបាយធ្វើដំណើរ Details of Conveyance**

ផ្លាកលេខ Plate No..... ប្រទេសចុះបញ្ជី Registering Country..... ចង្កូត Steering Wheel.....
ប្រភេទ Type..... ម៉ាក Brand..... ពណ៌ Color.....
លេខម៉ាស៊ីន Engine No..... លេខតួ Chassis No..... ឆ្នាំផលិត Manufacturing Year.....

**2- ព័ត៌មានម្ចាស់មធ្យោបាយធ្វើដំណើរ Details of Conveyance's Owner** (ក្នុងករណីម្ចាស់ជាអ្នកបើកបរ ពុំតម្រូវឱ្យបំពេញចំណុចលេខ "3" ខាងក្រោមនេះទេ)
(If owner of the conveyance is the driver, there is no need to fill number "3" below)

ឈ្មោះ Name..... សញ្ជាតិ Nationality..... ភេទ Sex.....
លេខលិខិតឆ្លងដែន Passport No..... ថ្ងៃខែឆ្នាំផ្តល់ Date of Issue.....
លេខប័ណ្ណព្រំដែន Border Pass No..... ថ្ងៃខែឆ្នាំផ្តល់ Date of Issue.....
លេខអត្តសញ្ញាណប័ណ្ណ Identity Card No..... ថ្ងៃខែឆ្នាំផ្តល់ Date of Issue.....
អាសយដ្ឋានស្នាក់នៅកម្ពុជា Address in Cambodia.....
រយៈពេលស្នាក់នៅកម្ពុជា Length of Stay in Cambodia.....

**3- ព័ត៌មានអ្នកបើកបរ Driver's Details**

ឈ្មោះ Name..... សញ្ជាតិ Nationality..... ភេទ Sex.....
លេខលិខិតឆ្លងដែន Passport No..... ថ្ងៃខែឆ្នាំផ្តល់ Date of Issue.....
លេខប័ណ្ណព្រំដែន Border Pass No..... ថ្ងៃខែឆ្នាំផ្តល់ Date of Issue.....
លេខអត្តសញ្ញាណប័ណ្ណ Identity Card No..... ថ្ងៃខែឆ្នាំផ្តល់ Date of Issue.....
អាសយដ្ឋានស្នាក់នៅកម្ពុជា Address in Cambodia.....
រយៈពេលស្នាក់នៅកម្ពុជា Length of Stay in Cambodia.....
ក្រុមហ៊ុនតំណាង Representative Company..... អាសយដ្ឋាន.....

**4- ព័ត៌មានផ្សេងៗ Other Information**

ក្រុមហ៊ុនធានាវ៉ាប់រង Insurance Company..... លេខ No..... ថ្ងៃខែឆ្នាំផ្តល់ Date of Issue.....
និមុត្តិធានា (បើតម្រូវ) Security (If required)..... បង្កាន់ដៃលេខ Receipt No..... ថ្ងៃខែឆ្នាំផ្តល់ Date of Issue.....

**5- កិច្ចសន្យាធានារ៉ះអាន Guarantee Agreement**

ខ្ញុំបាទ/នាងខ្ញុំ ឈ្មោះ I, Mr./Ms..... សូមសន្យាថានឹងនាំចូលមកវិញ/នាំចេញទៅវិញនូវមធ្យោបាយធ្វើដំណើរខាងលើ agree to return the above conveyance by ត្រឹមថ្ងៃខែឆ្នាំ date..... ។ ប្រសិនបើខ្ញុំបាទ/នាងខ្ញុំមិនគោរពតាមកិច្ចសន្យានេះ ខ្ញុំបាទ/នាងខ្ញុំយល់ព្រមទទួលខុសត្រូវចំពោះមុខច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ If I fail to comply with this agreement, I shall take full responsibility in accordance with the laws of the Kingdom of Cambodia.

ថ្ងៃទី Date..... ខែ Month..... ឆ្នាំ Year.....
ហត្ថលេខា Signature

| សម្រាប់មន្ត្រីគយ For Customs Officer Only | |
|---|---|
| ចូល ENTRY: ការិយាល័យគយនិងរដ្ឋាករ Customs and Excise Office..... | ចេញ EXIT: ការិយាល័យគយនិងរដ្ឋាករ Customs and Excise Office..... |
| ការបញ្ជាក់របស់មន្ត្រីគយ Customs Officer's Remarks | ការបញ្ជាក់របស់មន្ត្រីគយ Customs Officer's Remarks |
| ..... | ..... |
| ..... | ..... |
| បានឃើញនិងឯកភាព Seen and Approved<br>ប្រធានការិយាល័យ Chief of Office | ថ្ងៃទី Date..... ខែ Month..... ឆ្នាំ Year.....<br>មន្ត្រីគយ Customs Officers |
| បានឃើញនិងឯកភាព Seen and Approved<br>ប្រធានការិយាល័យ Chief of Office | ថ្ងៃទី Date..... ខែ Month..... ឆ្នាំ Year.....<br>មន្ត្រីគយ Customs Officers |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០.១.១.....សហវ.....

ថ្ងៃ...ខ...ឆ្នាំ...ទ សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២...ខែ... ឆ្នាំ២០១៨

## សេចក្តីណែនាំ
## ស្តីពី
## នីតិវិធី និងកិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការផ្ទេរប្រាក់ដុល្លារអាមេរិកពី រតនាគារ រាជធានី ខេត្ត មករតនាគារកណ្តាល

យោងសេចក្តីណែនាំលេខ ០០៤ សហវ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ ស្តីពីនីតិវិធីនៃការបង់ចំណូលជារូបិយប័ណ្ណបរទេសនៅរាជធានី ខេត្ត និងដើម្បីមានមូលដ្ឋានក្នុងការកត់ត្រាប្រតិបត្តិការផ្ទេរប្រាក់ជាប្រាក់ដុល្លារអាមេរិកពីរតនាគារ រាជធានី ខេត្ត មករតនាគារកណ្តាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចេញសេចក្តីណែនាំស្តីពីនីតិវិធី និងកិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការផ្ទេរប្រាក់ដុល្លារអាមេរិកពីរតនាគារ រាជធានី ខេត្ត មករតនាគារកណ្តាល មានខ្លឹមសារដូចខាងក្រោម÷

**១. ការទទួលចំណូលជាប្រាក់ដុល្លារអាមេរិក ដែលមន្ទីរជំនាញបានបង់ចូលគណនីចរន្តនៅរតនាគារ រាជធានី ខេត្ត÷**

**១.១.** ក្រោយពីរតនាគារ រាជធានី ខេត្ត បានទទួលប្រកាសឥណទាន ឬ ប័ណ្ណបង់ប្រាក់ ឬ របាយការណ៍ធនាគារ (Bank Statement) ស្តីពីការបង់ប្រាក់ដុល្លារអាមេរិករបស់មន្ទីរជំនាញចូលគណនីចរន្តរបស់រតនាគារ រាជធានី ខេត្ត នៅតាមធនាគារពាណិជ្ជដែលគ្រ គណនេយ្យករត្រូវកត់ត្រា÷

**កិច្ចបញ្ជិកាគណនេយ្យ រដ្ឋ នៅរតនាគារ រាជធានី ខេត្ត÷**

ឥណពន្ធ គណនី ចរន្តនៅធនាគារពាណិជ្ជ ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល(លេខ ១១២៦/១១៣៦)

ឥណទាន គណនី រដ្ឋទេយ្យករចំណូល (លេខ ៤៧០៤) ឬ

ឥណទាន គណនី ចំណូលបណ្តោះអាសន្ន (លេខ ៤៧០៥) ឬ

ឥណទាន គណនី ចំណូលផ្សេងៗនិងបង្សែរវង់ចាំដោះស្រាយ (លេខ៤៧០៦)។

<u>សក្តីបត្រ÷</u>

- ប្រកាសឥណទាន ឬ ប័ណ្ណបង់ប្រាក់ ឬ របាយការណ៍ធនាគារ (Bank Statement)
- លិខិតជូនដំណឹងឥណពន្ធ
- សលាកបត្រចុះលេខនា។

<u>បញ្ជាក់÷</u>

- នៅក្នុងគណនីចរន្តរបស់រតនាគារ រាជធានី ខេត្ត នៅធនាគារពាណិជ្ជដែលគ្រ ជាប្រាក់ដុល្លារអាមេរិកសម្រាប់ប្រតិបត្តិការចំណូល ត្រូវកត់ត្រាជាប្រាក់រៀល ដោយគិតតាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជានៅថ្ងៃ ខែ ឆ្នាំនៃប្រកាសឥណទាន ឬ ប័ណ្ណបង់ប្រាក់ ឬ របាយការណ៍ធនាគារ (Bank Statement)។ ការកត់ត្រាត្រូវយកតាមអត្រាប្តូរប្រាក់ផ្លូវការប្រចាំ



ផ្លូវលេខ ៥២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា ក្នុងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS។

- រតនាគាររាជធានី ខេត្ត ត្រូវតាមដានចំណូលជាប្រាក់រៀល អមដោយប្រាក់ដុល្លារអាមេរិកក្នុងបញ្ជីវិភាគគណនី ចរន្តនៅធនាគារពាណិជ្ជ ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល។

- គណនី រដ្ឋទេយ្យករចំណូល, គណនី ចំណូលបណ្តោះអាសន្ន និងគណនី ចំណូលផ្សេងៗនិងបង្វែរវង់ចាំដោះស្រាយត្រូវកត់ត្រាជាប្រាក់រៀលតែប៉ុណ្ណោះ។

១.២. មន្ទីរជំនាញ នៅតាមរាជធានី ខេត្ត ត្រូវរៀបចំសលាកបត្របង់ចំណូលថវិកា ដែលនឹងទទួលបានការឯកភាពរបស់រតនាគាររាជធានី ខេត្ត។ គណនេយ្យករត្រូវកត់ត្រា÷

**កិច្ចបញ្ជិកាគណនេយ្យរដ្ឋ នៅរតនាគាររាជធានី ខេត្ត÷**

ឥណពន្ធ គណនី រដ្ឋទេយ្យករចំណូល (លេខ ៤៧០៤) ឬ

ឥណពន្ធ គណនី ចំណូលបណ្តោះអាសន្ន (លេខ ៤៧០៥) ឬ

ឥណពន្ធ គណនី ចំណូលផ្សេងៗនិងបង្វែរវង់ចាំដោះស្រាយ (លេខ៤៧០៦)

ឥណទាន គណនី ចំណូលថវិកា (លេខ ៧..)។

<u>សក្តីបត្រ÷</u>

- សលាកបត្របង់ចំណូលថវិកា
- លិខិតជូនដំណឹងឥណពន្ធ
- សលាកបត្រចុះលេខនា។

**២. ការទទួលប្រាក់ចំណូលជាប្រាក់ដុល្លារអាមេរិក ដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានបង់ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត÷**

២.១. ក្រោយពីរតនាគាររាជធានី ខេត្ត បានទទួលប្រកាសឥណទាន ឬ ប័ណ្ណបង់ប្រាក់ ឬ របាយការណ៍ធនាគារ (Bank Statement) ស្តីពីការបង់ប្រាក់ដុល្លារអាមេរិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ចូលគណនីចរន្តនៅធនាគារពាណិជ្ជ ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល គណនេយ្យករត្រូវកត់ត្រា÷

- **កិច្ចបញ្ជិកាគណនេយ្យរដ្ឋ នៅរតនាគាររាជធានី ខេត្ត÷**

ឥណពន្ធ គណនី ចរន្តនៅធនាគារពាណិជ្ជជាប្រាក់ដុល្លារអាមេរិកសម្រាប់ប្រតិបត្តិការចំណូល(លេខ ១១២៦/១១៣៦)

ឥណទាន គណនី ប្រាក់បញ្ជើថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (លេខ ៤៤០២/ ៤៤០៣/ ៤៤០៤)។

<u>សក្តីបត្រ÷</u>

- ប្រកាសឥណទាន ឬ ប័ណ្ណបង់ប្រាក់ ឬ របាយការណ៍ធនាគារ (Bank Statement)
- លិខិតជូនដំណឹងឥណពន្ធ
- សលាកបត្រចុះលេខនា។

<u>បញ្ជាក់÷</u>

- នៅក្នុងគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដែគ្ន ជាប្រាក់ដុល្លារអាមេរិកសម្រាប់

ប្រតិបត្តិការចំណូល ត្រូវកត់ត្រាជាប្រាក់រៀល ដោយគិតតាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជានៅថ្ងៃ ខែ ឆ្នាំនៃប្រកាសឥណទាន ឬ ប័ណ្ណបង់ប្រាក់ ឬ របាយការណ៍ធនាគារ (Bank Statement)។ ការកត់ត្រាត្រូវយកតាមអត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា ក្នុងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS។

- រតនាគាររាជធានី ខេត្ត ត្រូវតាមដានចំណូលជាប្រាក់រៀល អមដោយប្រាក់ដុល្លារអាមេរិកក្នុងបញ្ជីវិភាគគណនី ចរន្ត នៅធនាគារពាណិជ្ជ ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល។

- គណនីប្រាក់បញ្ញើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (លេខ ៤៤០២/៤៤០៣/៤៤០៤) ត្រូវកត់ត្រាជាប្រាក់រៀល តែប៉ុណ្ណោះ។

- **កិច្ចបញ្ជិកាគណនេយ្យថវិការដ្ឋបាលថ្នាក់ក្រោមជាតិ នៅរតនាគាររាជធានី ខេត្ត÷**

ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅរតនាគារ (លេខ ១២០២/១២០៣/១២០៤)

ឥណទាន គណនី រដ្ឋទេយ្យករចំណូល (លេខ ៤៧០៤) ឬ

ឥណទាន គណនី ចំណូលបណ្តោះអាសន្ន (លេខ ៤៧០៥) ឬ

ឥណទាន គណនី ចំណូលផ្សេងៗនិងបង្វែររង់ចាំដោះស្រាយ (លេខ៤៧០៦)។

<u>សក្តីបត្រ÷</u>

- លិខិតជូនដំណឹងឥណពន្ធ ដែលទទួលបានពីគណនេយ្យករថវិការដ្ឋ
- សលាកបត្រចុះលេខនា។

<u>បញ្ជាក់÷</u> គណនីប្រាក់បញ្ញើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅរតនាគារ ត្រូវកត់ត្រាជាប្រាក់រៀល តែប៉ុណ្ណោះ។

២.២. រដ្ឋបាលថ្នាក់ក្រោមជាតិ ឬ អង្គភាពជំនួស ត្រូវរៀបចំសលាកបត្របង់ចំណូលថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនឹងទទួលបានការឯកភាពពីរតនាគាររាជធានី ខេត្ត។ គណនេយ្យករត្រូវកត់ត្រា÷

**កិច្ចបញ្ជិកាគណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ÷**

ឥណពន្ធ គណនី រដ្ឋទេយ្យករចំណូល (លេខ ៤៧០៤) ឬ

ឥណពន្ធ គណនី ចំណូលបណ្តោះអាសន្ន (លេខ៤៧០៥) ឬ

ឥណពន្ធ គណនី ចំណូលផ្សេងៗនិងបង្វែររង់ចាំដោះស្រាយ (លេខ៤៧០៦)

ឥណទាន គណនី ចំណូលថវិកា (លេខ ៧...)។

<u>សក្តីបត្រ÷</u>

- សលាកបត្របង់ចំណូលថវិកា
- លិខិតជូនដំណឹងឥណពន្ធ
- សលាកបត្រចុះលេខនា។

**៣. ការផ្ទេរប្រាក់ចំណូលជាប្រាក់ដុល្លារអាមេរិក ពីគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជ ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល ទៅគណនីចរន្តជាប្រាក់ដុល្លារអាមេរិករបស់រតនាគារថ្នាក់កណ្តាល នៅធនាគារជាតិនៃកម្ពុជា÷**

៣.១. ក្រោយពីមានការបង់ចំណូលជាប្រាក់ដុល្លារអាមេរិក ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្តនៅធនាគារពាណិជ្ជសម្រាប់ប្រតិបត្តិការចំណូល ធនាគារពាណិជ្ជដែគូនឹងផ្ទេរប្រាក់ជាស្វ័យប្រវត្តិទៅគណនីចរន្តរបស់រតនាគារកណ្តាលនៅធនាគារជាតិនៃកម្ពុជា (លេខ ០០០០០០០១៣៥៣៥)។

៣.២. ករណីធនាគារពាណិជ្ជដែគូផ្ទេរប្រាក់ពីគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល ទៅគណនីចរន្តជាប្រាក់ដុល្លារអាមេរិករបស់រតនាគារកណ្តាល នៅធនាគារជាតិនៃកម្ពុជាក្នុងថ្ងៃហើយស្មនៃ្ស សមតុល្យ÷

**- កិច្ចបញ្ជិកាគណនេយ្យរដ្ឋនៅរតនាគាររាជធានី ខេត្ត÷**

ឥណពន្ធ គណនី ទំនាក់ទំនង ផ្ទេរសាច់ប្រាក់ (លេខ ៤៣០១)

ឥណទាន គណនី ចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជ ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល (លេខ ១១២៦/១១៣៦)។

<u>សក្តីបត្រ÷</u>

- ប្រកាសឥណពន្ធ ឬ របាយការណ៍ធនាគារ (Bank Statement)
- លិខិតជូនដំណឹងឥណទាន
- ប្រកាសឥណទានរបស់រតនាគាររាជធានី ខេត្ត ស្តីពីការផ្ទេរសាច់ប្រាក់
- សលាកបត្រចុះលេខនា។

<u>បញ្ជាក់÷</u>

- ការកត់ត្រាក្នុងបញ្ជីវិភាគនៃគណនីចរន្តនៅធនាគារពាណិជ្ជ ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល ត្រូវរៀបចំឡើងជាប្រាក់រៀល អមដោយប្រាក់ដុល្លារអាមេរិក។

- នៅក្នុងគណនី ចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជ ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល ត្រូវកត់ត្រាជាប្រាក់រៀល ដោយគិតតាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជានៅថ្ងៃ ខែ ឆ្នាំនៃប្រកាសឥណទាន ឬ ប័ណ្ណបង់ប្រាក់ ឬ របាយការណ៍ធនាគារ (Bank Statement)។ ការកត់ត្រាត្រូវយកតាមអត្រាប្តូរប្រាក់ផ្លូវការប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា ក្នុងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS។

- ប្រកាសឥណទានរបស់រតនាគាររាជធានី ខេត្ត ស្តីពីការផ្ទេរប្រាក់ ត្រូវមានកំណត់សម្គាល់ចំនួនទឹកប្រាក់ជាដុល្លារអាមេរិក។

**- កិច្ចបញ្ជិកាគណនេយ្យរដ្ឋនៅរតនាគារកណ្តាល÷**

តាមរយៈប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS នៅតាមរតនាគាររាជធានី ខេត្ត លេខនាគណនេយ្យនៃប្រតិបត្តិការផ្ទេរសាច់ប្រាក់ នឹងត្រូវបានបង្ហាញដោយស្វ័យប្រវត្តិនៅក្នុងលេខនាគណនេយ្យរបស់រតនាគារថ្នាក់កណ្តាល ដូចខាងក្រោម÷

ឥណពន្ធ គណនី សាច់ប្រាក់បានទទួលពីរតនាគាររាជធានី ខេត្តរង់ចាំនិយ័តកម្ម (លេខ ៤៧០៣)

ឥណទាន គណនី ទំនាក់ទំនង ផ្ទេរសាច់ប្រាក់ (លេខ ៤៣០១)។

<u>បញ្ជាក់</u>÷

- ចំនួនទឹកប្រាក់នៃប្រតិបត្តិការផ្ទេរប្រាក់ ស្មើនឹងចំនួនទឹកប្រាក់រៀល ដែលរតនាគារជាធានី ខេត្ត បានកត់ត្រានៅពេលធនាគារពាណិជ្ជបានផ្ទេរប្រាក់ទៅរតនាគារកណ្តាល។

- ពេលទទួលបានប្រកាសឥណទាន ឬ របាយការណ៍ធនាគារ គណនេយ្យករត្រូវកត់ត្រា÷

**- កិច្ចបញ្ជិកាគណនេយ្យរដ្ឋនៅរតនាគារកណ្តាល÷**

ឥណពន្ធ គណនី ចរន្តនៅធនាគារជាតិនៃកម្ពុជា ជាប្រាក់ដុល្លារអាមេរិក (លេខ ១១០១០៦)

ឥណទាន គណនី សាច់ប្រាក់បានទទួលពីរតនាគារជាធានី ខេត្ត រង់ចាំនិយ័តកម្ម (លេខ ៤៧០៣)។

<u>សក្តីបត្រ</u>÷

- ប្រកាសឥណពន្ធ ឬ របាយការណ៍ធនាគារ (Bank Statement)
- លិខិតជូនដំណឹងឥណពន្ធ
- ប្រកាសឥណទានរបស់រតនាគារជាធានី ខេត្ត ស្តីពីការផ្ទេរប្រាក់
- សលាកបត្រចុះលេខនា។

<u>បញ្ជាក់</u>÷

- ការកត់ត្រាក្នុងបញ្ជីវិភាគនៃគណនីចរន្តរបស់រតនាគារកណ្តាល ជាប្រាក់ដុល្លារអាមេរិក នៅធនាគារជាតិនៃកម្ពុជា ត្រូវរៀបចំឡើងជាប្រាក់រៀល អមដោយប្រាក់ដុល្លារអាមេរិក។

- គណនី សាច់ប្រាក់បានទទួលពីរតនាគារជាធានី ខេត្តរង់ចាំនិយ័តកម្ម (លេខ៤៧០៣) ត្រូវស្មើនឹងសមតុល្យ។

៣.៣. ករណីដែលគណនីចរន្តរបស់រតនាគារជាធានី ខេត្ត នៅធនាគារពាណិជ្ជដែគ្ន ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល នៅហានសបតុល្យ ក្រោយពីប្រតិបត្តិការផ្ទេរប្រាក់ដុល្លារអាមេរិកទៅគណនីចរន្តជាប្រាក់ដុល្លារអាមេរិករបស់រតនាគារថ្នាក់កណ្តាលនៅធនាគារជាតិនៃកម្ពុជា ទឹកប្រាក់ដែលនៅសល់នឹងត្រូវផ្ទេរនៅថ្ងៃបន្ទាប់តាមអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា។ ករណីនេះអាចនាំឱ្យកើតមានចំនួនទឹកប្រាក់លម្អៀងជាប្រាក់រៀលនៅក្នុងគណនីចរន្តនៅធនាគារពាណិជ្ជជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល រវាងអត្រាប្តូរប្រាក់ថ្ងៃមុននិងថ្ងៃបន្ទាប់។ ចំនួនទឹកប្រាក់លម្អៀងនេះត្រូវបានជម្រះដោយចាត់ទុកជាចំណូលថវិកា (អនុគណនី ចំណេញពីអត្រាប្តូរប្រាក់ លេខ ៧៦០៦១) ឬ ជាចំណាយថវិកា (អនុគណនី ខាតពីអត្រាប្តូរប្រាក់ លេខ ៦៦៩៨១)។ នៅដំណាច់ខែនីមួយៗ គណនេយ្យករតនាគារជាធានី ខេត្ត ត្រូវគណនារកទឹកប្រាក់លម្អៀងពីអត្រាប្តូរប្រាក់នេះ និងត្រូវកត់ត្រាចំណេញ ឬ ខាតពីអត្រាប្តូរប្រាក់ ដោយពុំចាំបាច់មានសលាកបត្របង់ចំណូលថវិកា ឬ អាណត្តិបើកប្រាក់ទេ។

**- កិច្ចបញ្ជិកាគណនេយ្យរដ្ឋនៅរតនាគារជាធានី ខេត្ត÷**

ឥណពន្ធ គណនី ទំនាក់ទំនង ផ្ទេរសាច់ប្រាក់ (លេខ ៤៣០១)

ឥណទាន គណនី ចរន្តនៅធនាគារពាណិជ្ជ ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល (លេខ ១១២៦/១១៣៦)។

<u>សក្តីបត្រ</u>÷

- ប្រកាសឥណពន្ធ ឬ របាយការណ៍ធនាគារ (Bank Statement)

- លិខិតជូនដំណឹងឥណទាន
- ប្រកាសឥណពន្ធរបស់រតនាគារជាតិ ខេត្ត ស្តីពីការផ្ទេរប្រាក់
- សលាកបត្រចុះលេខនា។ និង

• *<u>ករណីកើតមានការខាតពីអត្រាប្តូរប្រាក់</u>*

ឥណពន្ធ គណនី ខាតពីអត្រាប្តូរប្រាក់ (លេខ ៦៦៩៨១)

ឥណទាន គណនី ចរន្តនៅធនាគារពាណិជ្ជ ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល (លេខ ១១២៦/១១៣៦)។

<u>សក្តីបត្រ</u>÷

- លិខិតជូនដំណឹងឥណពន្ធ
- សលាកបត្រចុះលេខនា។ ឬ

• *<u>ករណីកើតមានការចំណេញពីអត្រាប្តូរប្រាក់</u>*

ឥណពន្ធ គណនី ចរន្តនៅធនាគារពាណិជ្ជ ជាប្រាក់ដុល្លារអាមេរិក សម្រាប់ប្រតិបត្តិការចំណូល (លេខ ១១២៦/១១៣៦)

ឥណទាន គណនី ចំណេញពីអត្រាប្តូរប្រាក់ (លេខ ៧៦០៦១)។

<u>សក្តីបត្រ</u>÷

- លិខិតជូនដំណឹងឥណពន្ធ
- សលាកបត្រចុះលេខនា។

**- កិច្ចបញ្ជិកាគណនេយ្យរដ្ឋនៅរតនាគារថ្នាក់កណ្តាល÷**

តាមរយៈប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ FMIS នៅតាមរតនាគារជាតិ ខេត្ត លេខនាគណនេយ្យនៃប្រតិបត្តិការផ្ទេរសាច់ប្រាក់នឹងត្រូវបានបង្ហាញដោយស្វ័យប្រវត្តិនៅក្នុងលេខនាគណនេយ្យរបស់រតនាគារថ្នាក់កណ្តាល ដូចខាងក្រោម÷

ឥណពន្ធ គណនី សាច់ប្រាក់បានទទួលពីរតនាគារជាតិ ខេត្ត រង់ចាំនិយ័តកម្ម (លេខ ៤៧០៣)

ឥណទាន គណនី ទំនាក់ទំនង ផ្ទេរសាច់ប្រាក់ (លេខ ៤៣០១)។

<u>សក្តីបត្រ</u>÷

- ប្រកាសឥណពន្ធរបស់រតនាគារជាតិ ខេត្ត ស្តីពីការផ្ទេរប្រាក់។

៣.៤. ក្រោយពីទទួលបានប្រកាសឥណទាន ឬ របាយការណ៍ធនាគារ របស់ធនាគារជាតិនៃកម្ពុជា គណនេយ្យករត្រូវកត់ត្រា÷

**កិច្ចបញ្ជិកាគណនេយ្យរដ្ឋនៅរតនាគារកណ្តាល÷**

ឥណពន្ធ គណនី ចរន្ត នៅធនាគារជាតិនៃកម្ពុជា ជាប្រាក់ដុល្លារអាមេរិក (លេខ ១១០១០៦)

ឥណទាន គណនី សាច់ប្រាក់បានទទួលពីរតនាគារជាតិ ខេត្តរង់ចាំនិយ័តកម្ម (លេខ៤៧០៣)។

**សក្តីបត្រ÷**

- ប្រកាសឥណទាន ឬ របាយការណ៍ធនាគារ (Bank Statement)
- លិខិតជូនដំណឹងឥណពន្ធ
- សលាកបត្រចុះលេខនា។

**បញ្ជាក់÷** ការកត់ត្រាក្នុងគណនីចរន្តនៅធនាគារជាតិនៃកម្ពុជា ជាប្រាក់ដុល្លារអាមេរិក (លេខ ១១០១០៦) ត្រូវរៀបចំឡើង ជាប្រាក់រៀល អមដោយប្រាក់ដុល្លារអាមេរិកដោយយកតាមអត្រាប្តូរប្រាក់ប្រចាំថ្ងៃរបស់ធនាគារជាតិនៃកម្ពុជា តាមថ្ងៃខែនៅលើប្រកាសឥណទាន ឬ របាយការណ៍ធនាគារ (Bank Statement)។

**៤** ចំពោះចំណូលថវិកាជាប្រាក់ដុល្លារអាមេរិករបស់ឃុំ សង្កាត់ រតនាគាររាជធានី ខេត្ត ត្រូវស្នើសុំទៅរតនាគារថ្នាក់កណ្តាលផ្ទេរសាច់ប្រាក់ជារៀល ទៅគណនីចរន្តរបស់រតនាគាររាជធានី ខេត្តនៅធនាគារពាណិជ្ជ សម្រាប់ប្រតិបត្តិការចំណូល ចំណាយរបស់ឃុំ សង្កាត់ ដោយភ្ជាប់ជាមួយសលាកបត្របង់ចំណូល។

**៥.** សេចក្តីណែនាំលេខ ០០៤ សហវ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ ស្តីពីនីតិវិធីនៃការបង់ចំណូលជារូបិយប័ណ្ណបរទេសនៅរាជធានី ខេត្ត ត្រូវទុកជានិរាករណ៍។

គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញ អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ តទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ ហ្ស៊ុន ចាន់ណារ៉ា

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ធនាគារអេស៊ីលីដា ភី អិល ស៊ី
- ធនាគារកាណាឌីយ៉ា ក.អ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft

លេខ : ៣៧២...ក្រ.ហ.ក.ប្រ.ក.យ ថ្ងៃ....ពុធ...២០រោច..... ខែកក្កដា..... ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី....២៣... ខែកញ្ញា.. ឆ្នាំ២០១៨

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រផលិតគ្រឿងសំអាង "Cosmetic Products" និងសំបកជបគ្រឿងសំអាង "Plastic tubes/bottles for Cosmetics Products" ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៨ របស់ក្រុមហ៊ុន មីង ហ្វៃ អេនធើប្រាយ (ខេមបូឌា) ឯ.ក

## ស ម្រេ ច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន មីង ហ្វៃ អេនធើប្រាយ (ខេមបូឌា) ឯ.ក (MING FAI ENTERPRISE (CAMBODIA) CO., LTD.) តំណាងដោយលោក **CHING TOMMY TSUN-WAH** បង្កើតរោងចក្រផលិតគ្រឿងសំអាង "**Cosmetics Products**" និងសំបកជបគ្រឿង សំអាង "**Plastic tubes/bottles for Cosmetics Products**" ដែលមានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤១ (ផ្លូវព្រះអង្គឌួង) ភូមិវាលវង់ ឃុំសែនជ័យ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax: 855-23-428263

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១- គ្រឿងសំអាង (Cosmetics Products) | ២០២៣ |
| ២- សំបកគ្រឿងសំអាងពីប្លាស្ទិក (Plastic tubes/ Bottles for cosmetics products) | ២២២០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្ទាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ឆ្លាកឈ្មោះរោងចក្រ៖** " រោងចក្រផលិតគ្រឿងសំអាង "Cosmetic Products" និងសំបកដបគ្រឿងសំអាង "Plastic tubes/bottles for Cosmetic Products" មីង ហ្ស្ហ្ស អេនធើប្រាយ (ខេមបូឌា) ឯ.ក "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៨នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំងការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសម្រាមឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្ម ច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាម មាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

ហ៊ាង សុខគង់

ទទួលខុសនៃ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-អគ្គនាយកដ្ឋានពន្ធដារ និងសេវាកុំព្យូទ័រ
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តកំពង់ស្ពឺ
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ
-រដ្ឋបាលស្រុកសំរោងទង
-រដ្ឋបាលឃុំសែនជ័យ
"ដើម្បីជូនជ្រាប"
-ផ្ទៃប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៣២៣..ឧស.ក្រ.ប្រកាស

ថ្ងៃ..ព្រហស្បតិ៍..ពាក់..ខែ..ភាទ..ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..២៧..... ខែកញ្ញា.. ឆ្នាំ២០១៨

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ របស់ក្រុមហ៊ុន វ៉ូ តាយ (ខេមបូឌា) ហ្គាមុិន ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន វ៉ូ តាយ (ខេមបូឌា) ហ្គាមុិន ឯ.ក (WUA TAI (CAMBODIA) GARMENT CO., LTD.) តំណាងដោយលោក **MU, JIANJUN** បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ភូមិត្រពាំងលើក សង្កាត់ការធ្លាក់ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។


៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax: 855-23-428263

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្ទាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្ទាកឈ្មោះរោងចក្រ៖** " រោងចក្រកាត់ដេរសម្លៀកបំពាក់ រ្ជយ តាយ (ខេមបូឌា) ហ្គាមុិន "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាម មាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ហេង សុខគង់**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តកំពង់ស្ពឺ
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ
-រដ្ឋបាលក្រុងច្បារមន
-រដ្ឋបាលសង្កាត់ការដេ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft

លេខ : ៧២២.ឧស.នក.ប្រកាស

ថ្ងៃ.ព្រហស្បតិ៍...ភ១ភ.. ខែ.មករា.ឆ.ត. ឆ្នាំ.ច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២៧.... ខែ.មករា.. ឆ្នាំ២០១៨

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រផលិតអំពូលក្លើងលំអ ខ្សែក្លើង និងកេសកាតុង ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៨ របស់ក្រុមហ៊ុន បៃ ហុង ខេមបូ ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន បៃ ហុង ខេមបូ ឯ.ក (BAI HONG CAMBO CO., LTD.) តំណាងដោយ លោក **HU QINGHUI** បង្កើតរោងចក្រ ផលិតអំពូលក្លើងលំអ ខ្សែក្លើង និងកេសកាតុង ដែលមានទីតាំងស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេសស្វាយរៀង ហ្គីហ្គា រីសស៍ (ផ្លូវជាតិលេខ១ ភូមិដើមពោធិ៍ ឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង) ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax: 855-23-428263

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១- អំពូលភ្លើងលំអ | ២៧៤០ |
| ២- ខ្សែភ្លើងមានក្បាលឆុយស្រាប់ | ២៧៩០ |
| ៣- កេសកាតុង | ១៧០២ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្ទាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្ទាកឈ្មោះរោងចក្រ៖** "រោងចក្រផលិតអំពូលភ្លើងលំអ ខ្សែភ្លើង និងកេសកាតុង បៃ ហុង ខេមបូ ឯ.ក "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំងការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាម មាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ហេង សុខគង់**

ទទួលខុសនៃ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកំពូទ័រ
-វិទ្យាស្ថានស្តង់ដារកម្ពុជា
-មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ
-សាលាខេត្តស្វាយរៀង
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តស្វាយរៀង
-អង្គភាពរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសស្វាយរៀង ហ្ស៊ីហ្គោ រ៉ែសស៍
-រដ្ឋបាលស្រុកស្វាយទាប
-រដ្ឋបាលឃុំកណ្តៀងរាយ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៨ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី